# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី ៥ ខែ តុលា ឆ្នាំ២០២០

## ស្ថានទូតអូស្ត្រាលី និងសាកលវិទ្យាល័យមួយចំនួន នៅកម្ពុជា ប្រារព្ធទិវាលំនៅដ្ឋានពិភពលោក

ឯកអគ្គរាជទូតអូស្ត្រាលី ប្រចាំកម្ពុជា ឯកឧត្តម Pablo Kang និងបុគ្គលិកស្ថានទូតអូស្ត្រាលី មានសេចក្តីរីករាយដែលបានចូលរួមក្នុងពិធីដាំកូនឈើ រួមគ្នាជាមួយ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងក្រសួងបរិស្ថាន ក្នុងទិវាលំនៅដ្ឋានពិភពលោក World Habitat Day នៅថ្ងៃទី ០៥ ខែតុលា នេះ។

ឯកអគ្គរាជទូត Kang បានមានប្រសាសន៍ថា "ទាំងមន្រ្តីស្ថានទូត ទាំងរូបខ្លួនខ្ញុំផ្ទាល់ ពិតជាមានកិត្តិយសណាស់ ដែលបានចូលរួមក្នុងពិធីដាំកូនឈើ ដោយសហការជាមួយ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងក្រសួងបរិស្ថាន"។

ឯកឧត្តម ឯកអគ្គរាជទូត Kang បានកត់សម្គាល់ថា ព្រឹត្តិការណ៍នេះសឱ្យឃើញនូវ អាទិភាពចំនួន ៣សំខាន់ៗ សម្រាប់ស្ថានទូតអូស្ត្រាលី ប្រចាំកម្ពុជា។

ឯកអគ្គរាជទូត Kang ក៏បានបន្តទៀតថា "អូស្ត្រាលីប្តេជ្ញាពង្រឹងទំនាក់ទំនងអប់រំជាមួយស្ថាប័នអប់រំនានានៅកម្ពុជាទាំងក្នុងពុទ្ធចក្រ និងអណាចក្រ ព្រមទាំងសហការជាមួយបណ្តាក្រុមសហគមន៍ដទៃទៀតនៅទីនេះ និងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងតំបន់ សំដៅលើកកម្ពស់បរិស្ថានក្នុងរាជធានីភ្នំពេញ។ ព្រឹត្តិការណ៍មួយនេះបានជួយឱ្យយើងឈានទៅដល់គោលដៅទាំងបីក្នុងពេលតែមួយ" ។

ទិវាលំនៅដ្ឋានពិភពលោក ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៨៥។ ទិវានេះ ជាការក្រានរំឭកដល់យើងទាំងអស់គ្នា ឱ្យមានទំនួលខុសត្រូវ ជំរុញអភិវឌ្ឍន៍ទីក្រុងប្រកបដោយនិរន្តរភាព តាមរយៈការយកចិត្តទុកដាក់ និងបញ្ចូលធម្មជាតិទៅក្នុងផែនការអភិវឌ្ឍន៍ក្រុងរបស់យើង។

អូស្ត្រាលីគាំទ្រដល់ការអភិវឌ្ឍបៃតងនៅប្រទេសកម្ពុជា និងបានផ្តល់ថវិកាសម្រាប់កូនឈើចំនួន ១៥០ និងសម្ភារៈដាំដុះផ្សេងៗទៀត ក្នុងបរិវេណវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

ឯកអគ្គរាជទូត Kang បានថ្លែងអំណរព្រះគុណដល់ សម្តេចព្រះមហាអរិយវង្ស បណ្ឌិត ឃី សុវណ្ណរតនា សាកលវិទ្យាធិការ នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ដែលបានផ្តួចផ្តើមសកម្មភាពនេះ។ ក៏សូមថ្លែងអំណរគុណដល់ ឯកឧត្តមបណ្ឌិត អ៊ុម រម្យណី អគ្គនាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដែលបានធ្វើជាម្ចាស់ផ្ទះនាទិវានេះ និងសូមអរគុណដល់ ឯកឧត្តម សូ សិង្ហា តំណាង ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

ឯកអគ្គរាជទូត Kang បានមានប្រសាសន៍ថា "ពេលខ្លះ យើងទំនងជាពិបាករកឱកាសអភិរក្សនៅតាមទីក្រុងធំ ដូចជារាជធានីភ្នំពេញជាដើម។ ប៉ុន្តែ សម្តេចព្រះមហាអរិយវង្ស បណ្ឌិត ឃី សុវណ្ណរតនា តែងតែបានក្រានរំឭកយើងទាំងអស់គ្នាថា យើងពិតជាអាចធ្វើបានបើយើងសហការគ្នា"។

**ទំនាក់ទំនងព័ត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au



ឯកឧត្តម សូ សិង្ហា និង ឯកអគ្គរាជទូត Pablo Kang កំពុងដាំកូនឈើរួមគ្នា